# មេរៀនទី ៦៦៖ ជីវិតនៃការដើរតាមព្រះយេស៊ូវ

## ម៉ាកុស ៨៖៣១-៣៨

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/gLDUG5AAjhQ

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/rTV3NoOrDEg

**គោលបំណង៖** ការប្ដេជ្ញាក្នុងការដើរតាមព្រះយេស៊ូវ

**ខគម្ពីរចងចាំ៖ ម៉ាកុស ៨៖៣៤** *“...... អ្នកណាដែលចង់មកតាមខ្ញុំ ត្រូវឲ្យអ្នកនោះលះកាត់ចិត្តខ្លួនឯងចោល ទាំងផ្ទុកឈើឆ្កាងខ្លួនមកតាមខ្ញុំចុះ”។*

**ចំរៀង** ( *យូធូបលីង* )៖

១. ខ្ញុំបានសម្រេចចិត្ត https://youtu.be/MR1Yv--Q4oo
២. ខ្ញុំដើរតាមព្រះយេស៊ូវ https://youtu.be/aasilZXGorc
៣. គឺជាការល្អ https://youtu.be/Z91SULEHfho

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត **«អៀវប្រណាំង»**



១. ចែកកុមារជា២ក្រុម ហើយឲ្យពួកគេឈរជាជួរជាមួយដៃគូរបស់ពួកគេ

២. ហើយនេះគឺជាការអៀវប្រណាំង ដូច្នេះដៃគូត្រូវសម្រេចចិត្តអ្នកណាជាអ្នកអៀវ

៣. នៅពេលដែលគ្រូស្រែកថា “រត់” កុមារត្រូវរត់មកខាងមុខដោយអៀវដៃគូ របស់ពួកគេ។ ហើយគូណាដែលរត់ទៅដល់ទីមុនគេក្រុមនោះ នឹងទទួលបាន ១ ពិន្ទុ

៤. នៅពេលដែលគូទី១ បានទៅដល់ទីហើយ គ្រូសូមឲ្យគូបន្ទាប់រត់បន្ត

៥. ក្រុមណាដែលបានពិន្ទុច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។

## ៤. ការណែនាំមេរៀន



យកកាតាបស្ពាយធ្ងន់មួយ ហើយឲ្យកុមារស្ពាយកាតាបនោះ រួចឲ្យគាត់ដើរជុំវិញថ្នាក់រៀនម្នាក់មួយជុំម្នាក់។សួរកុមារថាកាតាបស្ពាយនេះធ្ងន់ឬអត់សម្រាប់ពួកគេ។

មានបុរសម្នាក់គាត់បានលីឈើឆ្កាងយ៉ាងធ្ងន់ សម្រាប់ពួកយើងដល់ស្លាប់ ម្នាក់នោះគឺ ព្រះយេស៊ូវ។

តើទ្រង់បានធ្វើអ្វីមួយអាក្រក់មែនដែរឬទេ? (អត់ទេ!) ព្រះយេស៊ូវមិនសាកសមនឹងសុគតនៅលើឈើឆ្កាងនោះទេ ប៉ុន្តែទ្រង់បានធ្វើវាដោយសារសេចក្ដីស្រឡាញ់ដ៏ធំធេងរបស់ទ្រង់ ចំពោះយើង និងការស្ដាប់បង្គាប់ព្រះវរបិតាទ្រង់។ ថ្ងៃនេះយើងនឹងរៀនអំពីព្រះយេស៊ូវបានប្រាប់ពួកសិស្ស របស់

ទ្រង់អំពីផែនការ របស់ព្រះវរបិតាសម្រាប់ព្រះអង្គ។ ហើយទ្រង់ក៏នឹង ប្រាប់រឿងរ៉ាវសំខាន់មួយចំនួនសម្រាប់យើងទាំងអស់គ្នា ក្នុងការដើរតាមព្រះអង្គដែរ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ព្រះយេស៊ូវបានសម្តែងពីការអស្ចារ្យជាច្រើន! ហើយឥឡូវនេះពួកសិស្សបានដឹងហើយថា ទ្រង់ជាព្រះមេស្ស៊ី។ ព្រះមេស្ស៊ីគឺជា ម្នាក់ដែលព្រះវរបិតាបានបញ្ជូនមកក្នុងការសង្គ្រោះរាស្ត្ររបស់ទ្រង់។ ពេត្រុសគឺជាសិស្សម្នាក់ក្នុងចំណោមសិស្សទាំង ១២នាក់ របស់ព្រះយេស៊ូវ ហើយគាត់ទើបតែបានប្រកាសថាគាត់មានជំនឿលើព្រះយេស៊ូវជាព្រះមេស្ស៊ីតែប៉ុណ្ណោះ។ ហើយឥឡូវនេះ ព្រះយេស៊ូវចង់បង្រៀនពួកគេពីកិច្ចការសំខាន់មួយចំនួន ដែលព្រះវរបិតាមានផែនការសម្រាប់ព្រះមេស្ស៊ី។

ព្រះគម្ពីរ **ម៉ាកុស ៨៖៣១** បាននិយាយថា "រួចទ្រង់ចាប់តាំងបង្រៀនគេថា កូនមនុស្សត្រូវរងទុក្ខជាច្រើន ហើយត្រូវពួកចាស់ទុំ ពួកសង្គ្រាជ និងពួកអាចារ្យបោះបង់ចោល ហើយសំឡាប់លោក រួច៣ថ្ងៃក្រោយដែលលោកស្លាប់ទៅ នោះលោកនឹងរស់ឡើងវិញ" ។ ព្រះយេស៊ូវបានប្រាប់ពួកគេត្រង់ៗពីអ្វីដែលនឹងត្រូវកើតឡើងចំពោះទ្រង់។ ទាំងនេះមិនមែនជាអ្វីដែលពួកសិស្សត្រូវឮអំពីព្រះយេស៊ូវនោះទេ! ពួកគេជឿថាព្រះមេស្ស៊ីនឹងមានលក្ខណៈដូចជាស្តេច និងដឹកនាំមនុស្សគ្រប់គ្នាឲ្យដើរត្រឹមត្រូវ។

ពេត្រុសជឿថាព្រះយេស៊ូវគឺជាព្រះមេស្ស៊ី ប៉ុន្តែអ្វីដែលព្រះយេស៊ូវបានប្រាប់ពួកគេគឺទ្រង់នឹងត្រូវសុគតនៅលើឈើឆ្កាង ពេត្រុសស្តីបន្ទោសទ្រង់! នេះគឺមានន័យថា ពេត្រុស ស្តីបន្ទោសព្រះយេស៊ូវ ថាទ្រង់កំពុងតែនិយាយនូវអ្វីដែលខុស។ ប៉ុន្តែរំពេចនោះព្រះយេស៊ូវស្តីបន្ទោសពេត្រុសថា " សាតាំងអើយ ចូរថយទៅក្រោយអញទៅ ដ្បិតឯងមិនគិតតាមគំនិតរបស់ព្រះសោះ គឺតាមតែគំនិតរបស់មនុស្សលោកវិញ!" ។

បន្ទាប់មកព្រះយេស៊ូវក៏បានពន្យល់ទៅកាន់ពួកសិស្សរបស់ទ្រង់ថា **ម៉ាកុស ៨៖៣៤-៣៦** "កាលទ្រង់បានហៅហ្វូងមនុស្ស និងពួកសិស្សមក នោះក៏មានព្រះបន្ទូលទៅគេថា អ្នកណាដែលចង់មកតាមខ្ញុំត្រូវឲ្យអ្នកនោះលះកាត់ចិត្តខ្លួនឯងចោល ទាំងផ្ទុកឈើឆ្កាងខ្លួនមកតាមខ្ញុំចុះ ដ្បិតអ្នកណាដែលចង់ឲ្យរួចជីវិត នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលបាត់ជីវិតដោយព្រោះយល់ដល់ខ្ញុំ ហើយនិងដំណឹងល្អនោះនឹងបានជីវិតវិញ ដ្បិតបើមនុស្សណានឹងបានលោកីយ៍ទាំងមូល តែបាត់ព្រលឹងទៅ នោះតើមានប្រយោជន៍អ្វីដល់អ្នកនោះ" ។

ការដើរតាម ព្រះយេស៊ូវ វាមិនមែនជារឿងងាយស្រួលនោះទេ។ វាមិនមែនមានន័យថាយើងគ្រាន់តែចង់ផ្ទេរនូវអំពើបាបរបស់យើងទៅចំពោះទ្រង់តែប៉ុណ្ណោះទេ ប៉ុន្តែគឺយើងត្រូវតែរស់នៅឲ្យដូចជាព្រះយេស៊ូវផងដែរ។ នេះគឺមានន័យថា យើងត្រូវតែធ្វើនូវអ្វីដែលព្រះចង់ឲ្យយើងធ្វើមិនថារឿងនោះវាលំបាកយ៉ាងណាក៏ដោយ។ ហើយវាមានន័យថា កុំឲ្យយើងគិតពីប្រយោជន៍ផ្ទាល់ខ្លួន ប៉ុន្តែត្រូវគិតពីអ្នកដទៃវិញ។ វាគឺពិបាក ដូចជាការលីឈើឆ្កាងអីចឹង។ ព្រះយេស៊ូវបានលីឈើឆ្កាងរបស់ទ្រង់ និងបានលះបង់ជីវិតរបស់ទ្រង់សម្រាប់យើង។ ព្រះយេស៊ូវចង់ឲ្យពួកយើងបានប្រគល់ជីវិតរបស់យើង និងរស់នៅសម្រាប់ទ្រង់ មិនមែនសម្រាប់យើងនោះទេ មិនថាវាលំបាកក្នុងការធ្វើយ៉ាងណាក៏ដោយ។ មិនថាពេលខ្លះវាស្តាប់ទៅដូចជាពិបាកបន្តិច តែព្រះយេស៊ូវបានសន្យាថាទ្រង់នឹងគង់នៅជាមួយពួកយើង នាំផ្លូវយើង និងជួយដល់យើង! យើងគឺមិន ឯកោនោះទេនៅពេលដែលយើងដើរតាមព្រះយេស៊ូវ ពីព្រោះថា ទ្រង់តែងតែគង់ជាមួយយើងជានិច្ច!

## ៦. សំនួរពិភាក្សា

១.តើពេត្រុសបានធ្វើអ្វីនៅពេលដែលព្រះយេស៊ូវបានពន្យល់ពីពេលដែលទ្រង់ត្រូវសុគត ហើយបីថ្ងៃក្រោយទ្រង់និងមានព្រះជន្មរស់ឡើងវិញ? *(ពេត្រុសស្តីបន្ទោសព្រះយេស៊ូវ)*

២. តើព្រះយេស៊ូវបានមានបន្ទូលអ្វីខ្លះក្នុងការដែលឲ្យមនុស្សក្លាយទៅជាសិស្សរបស់ទ្រង់? *(កាត់ចិត្តខ្លួនឯងចោល ទាំងផ្ទុកឈើឆ្កាងខ្លួនមកតាមខ្ញុំចុះ)*

៣.ហេតុអ្វីបានជាការដើរតាមព្រះយេស៊ូវពិបាក? *(គឺមានន័យថាយើងត្រូវស្តាប់បង្គាប់ព្រះ និងមិនប្រព្រឹត្តអំពើបាប)*

៤. តើនរណាបានលីឈើឆ្កាងសម្រាប់យើង? *(ព្រះយេស៊ូវ)*

៥.តើអ្វីដែលធ្វើឲ្យយើងមានភាពងាយស្រួលក្នុងការលីឈើឆ្កាង? *(ព្រះយេស៊ូវតែងតែគង់នៅជាមួយយើង ហើយជួយយើង)*

## ៧. ល្បែងកំសាន្ត

សម្ភារៈដែលត្រូវការ៖ ក្រដាសរាម៥សន្លឹក និង ដុំថ្មតូចៗ



១. បិតក្រដាសជារូបរាងឈើឆ្កាងនៅលើដី

២. ចែកកុមារជា ពីរក្រុម ហើយឲ្យពួកគេឈរជាជួរប្រហែល ៥ ជំហានពីឈើឆ្កាង

៣. ឲ្យដុំថ្មតូចៗទៅក្រុមនីមួយៗ ហើយឲ្យពួកគេបោះវាទៅលើឈើឆ្កាងនោះ។ ប្រសិនបើវាធ្លាក់ទៅលើឈើឆ្កាង ពួកគេនិងទទួលបាន ១ ពិន្ទុ។ ប៉ុន្តែប្រសិនបើវាធ្លាក់ចេញក្រៅ ពួកគេនឹងមិនទទួលបានពិន្ទុនោះទេ។

៤. មុនពេលដែលកុមារបោះដុំថ្មនោះ សូមឲ្យពួកគេនិយាយថា “ខ្ញុំដើរតាមព្រះយេស៊ូវ!” ។

## ៨. ខគម្ពីរចងចាំ

**ម៉ាកុស ៨៖៣៤** *“...... អ្នកណាដែលចង់មកតាមខ្ញុំ ត្រូវឲ្យអ្នកនោះលះកាត់ចិត្តខ្លួនឯង ចោលទាំងផ្ទុកឈើឆ្កាងខ្លួនមកតាមខ្ញុំចុះ”។*

## ៩. ហត្ថកម្ម «បង្កើតឈើឆ្កាងរបស់អ្នក»

សម្ភារៈដែលត្រូវការ៖ ក្រដាសពណ៌ និងកាវ



១. ឲ្យក្រដាសពណ៌ខុសៗគ្នាទៅកុមារ ហើយឲ្យពួកគេហែកវាជាបំណែកតូចៗ ដើម្បីបិតវានិងក្រដាសធំមួយទៀតជារាងឈើឆ្កាង

២. សូមពន្យល់ដល់កុមារថា ព្រះយេស៊ូវបានលីឈើឆ្កាងដ៏ធ្ងន់ ដើម្បីកុំឲ្យយើងត្រូវស្លាប់ដោយសារអំពើបាបរបស់យើង។ យើងត្រូវតែអរព្រះគុណដល់ព្រះ ហើយតាំងចិត្តដើរតាមព្រះអង្គ។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

វាពិបាកណាស់ក្នុងការតាំងចិត្តធ្វើតាមនរណាម្នាក់ដែលអ្នកមិនអាចទុកចិត្តបាន។ ការប្តេជ្ញាចិត្តគឺជាការសន្យាថានឹងធ្វើអ្វីមួយ ទោះបីជាមានការលំបាកក៏ដោយ។ យើងត្រូវចាំថា ព្រះយេស៊ូវបានតាំងចិត្តដើម្បីសង្គ្រោះយើង ហើយទ្រង់មិនបានផ្លាស់ប្តូរគំនិត សូម្បីតែនៅពេលដែលមានការលំបាកសម្រាប់

ទ្រង់ — សូម្បីតែទ្រង់ត្រូវសុគតនៅលើឈើឆ្កាងក៏ដោយ។ ដោយសារព្រះយេស៊ូវបានសុគតសម្រាប់យើង ហើយយើងអាចទុកចិត្តលើព្រះយេស៊ូវបាន។ យើងដឹងថាគ្មានអ្វីដែលព្រះយេស៊ូវនឹងមិនអាចធ្វើសម្រាប់យើងដោយសារទ្រង់ស្រឡាញ់យើង។ ថ្ងៃនេះ សូមឲ្យយើងតាំងចិត្តដើរតាមព្រះយេស៊ូវពេញមួយជីវិតរបស់យើង។